# អ្នកនាំសារ
# The Messenger

39

ខែតុលា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



## ឪពុកម្តាយជាមាគ៌ានាំកូនទៅរកការអប់រំ



សន្និបាតបេសក-កម្មនៃព្រះសហគមន៍ទ្វីបអាស៊ី
ទំព័រ ៦



បិទវគ្គបំប៉នកុមារព្រះសហគមន៍ភូមិប៉ាង កំពង់ធំ
ទំព័រ ១១

យើងដើរតាមគន្លងរបស់ព្រះជាម្ចាស់
ទំព័រ ១២

# សំនួរក្មេងៗ

## ស្វែងយល់ពាក្យក្នុងគម្ពីរ !




ប្អូនៗធ្លាប់បានឮពាក្យខ្លះៗ ដែលមានសរសេរក្នុងគម្ពីរដូចជា : គណៈផារីស៊ី គណៈសាឌូស៊ី បណ្ឌិតខាងវិន័យ ឬបូជាចារ្យ។ ពាក្យទាំងនេះមានន័យអ្វី ?

**គណៈផារីស៊ី :** គឺជាជនជាតិយូដាមួយក្រុមដែលយកចិត្តទុកដាក់គោរពធម្មវិន័យរបស់លោកម៉ូសេដោយហ្មត់ចត់។ ពួកគេចូលចិត្តប្រតិបត្តិតាមប្រពៃណីដូនតា ហើយគិតស្មានថា នឹងបានទៅជាមនុស្សសុចរិតដោយការប្រតិបត្តិតាមវិន័យយ៉ាងហ្មត់ចត់នេះ។

**គណៈសាឌូស៊ី :** ជនជាតិយូដាមួយក្រុមដែលតែងពន្យល់គម្ពីរវិន័យតាមបែបផ្សេងពីគណៈផារីស៊ី។ ពួកគេមិនជឿថាមានទេវទូត ឬខ្មោច និងមិនជឿថា មនុស្សស្លាប់ ហើយរស់ឡើងវិញនោះទេ។

**បណ្ឌិតខាងវិន័យ :** គ្រូអាចារ្យដែលតែងតែរៀនគម្ពីរទាំងមូល ជាពិសេសគម្ពីរវិន័យរបស់លោកម៉ូសេដោយពិនិត្យពិច័យនូវការប្រៀនប្រដៅដែលមានចែងទុកក្នុងគម្ពីរ ហើយយកចំណេះរបស់ខ្លួនទៅបង្រៀនអ្នកស្រុក។ គ្រិស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យអាចារ្យ។ ខ្លះទៀតប្រើពាក្យធម្មាចារ្យ។

**បូជាចារ្យ :** ជាអាចារ្យ ដែលទទួលមុខងាររៀបចំតង្វាយ ឬធ្វើបូជាយញ្ញថ្វាយព្រះជាម្ចាស់តាមវិន័យរបស់លោកម៉ូសេ។ លោកបូជាចារ្យមានភារកិច្ចបង្រៀនអ្នកស្រុកអំពីគម្ពីរវិន័យផងដែរ។

ជំនាន់ព្រះយេស៊ូ ពួកនាយកបូជាចារ្យជាមេអស់លោកបូជាចារ្យ។ ហើយលោកមហាបូជាចារ្យជាប្រមុខនៃលោកបូជា-ចារ្យទាំងអស់។ គ្រិស្តបរិស័ទខ្លះធ្លាប់ប្រើពាក្យ "សង្ឃ" សម្រាប់បូជាចារ្យ "សម្ដេចសង្ឃ" សម្រាប់មហាបូជា-ចារ្យ។ ខ្លះទៀតប្រើពាក្យ "សង្ឃរាជ"។

អ្នកនាំសារ

# អធិប្បាយព្រះបន្ទូល

### ថ្ងៃទី ០៨ តុលា ២០០៦ ត្រូវនឹងថ្ងៃអាទិត្យទី ២៧ ប្រចាំឆ្នាំ "ខ"

## "បុរសត្រូវចាកចេញពីឪពុកម្ដាយទៅរួមរស់ជាមួយភរិយារបស់ខ្លួន"

(ម៉ាកុស ១០,២-១៦)

តាមគម្ពីរគូស្វាមីភរិយាជារូបតំណាងព្រះជាម្ចាស់ (កណ១,២៩)។ អ្នកទាំងពីរបន្តជីវិតជាចំណែកមួយនៃព្រះជន្មផ្ទាល់របស់ព្រះអង្គក្នុងខ្លួនមនុស្សយើង។ បងប្អូនដែលមានគ្រួសារ សូមរិះគិតពីតម្លៃដ៏ថ្លៃថ្នូរនៃក្ដីស្នេហាដែលធ្វើឱ្យបងប្អូនអាចបន្តព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ ឱ្យកូន! ហេតុនេះ គូស្វាមីភរិយាត្រូវមានចិត្តដូចព្រះជាម្ចាស់ ត្រូវតែស្មោះស្ម័គ្រភក្ដីគ្នា ដូចព្រះអង្គដែលស្មោះភក្ដីជាមួយប្រជារាស្ត្រដែរ (ហស២,១៦)។ ការរស់នៅជាគូស្វាមីភរិយាមិនគ្រាន់តែជារឿងកិលេសតណ្ហា ឬសម្រាប់តែបន្តជីវិតនោះទេ គឺជាប់ជំពាក់ជំពិនជាមួយព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិត និងនៃសេចក្ដីស្រឡាញ់។

តាមអរិយធម៌ខ្មែរ ភរិយាតែងតែស្មោះស្ម័គ្រនឹងស្វាមី រីឯស្វាមីមិនសូវស្មោះទេ តែងក្បត់ចិត្តភរិយាទៅលេងស្រីពេស្យា និងទុកថាធម្មតា។ ជនជាតិយូដាជំនាន់ព្រះយេស៊ូក៏ដូចគ្នា គេក៏មិនសូវរវីរវល់ស្មោះត្រង់នឹងភរិយាដែរ។ ត្រង់នេះយើងជាគ្រិស្តបរិស័ទ ប្រព្រឹត្តខុសប្លែកពីអ្នកដទៃ ដោយធ្វើជាសាក្សីអំពី



សម្ព័ន្ធមេត្រីនៃព្រះជាម្ចាស់ ដែលស្រឡាញ់មនុស្សមិនដែលដាច់ឡើយ។ ជួនកាលស្វាមីភរិយាទ្រាំរស់នៅជាមួយគ្នាមិនកើត ដោយមូលហេតុផ្សេងៗ តែត្រូវដឹងថា ការបែកគ្នានោះគឺពុំស្របតាមព្រះហឫទ័យព្រះជាម្ចាស់ទេ។ យើងត្រូវតែសូមអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះវិញ្ញាណមកបំភ្លឺចិត្តគំនិត យើងគ្រប់ៗគ្នា ឱ្យយល់អំពីតម្លៃដ៏ថ្លៃថ្នូរនៃសេចក្ដីស្នេហា។

### ថ្ងៃទី ១៥ តុលា ២០០៦ ត្រូវនឹងអាទិត្យទី ២៨ ប្រចាំឆ្នាំ "ខ"

## "អញ្ជើញទៅលក់អ្វីៗ ទាំងអស់ដែលអ្នកមាន ចែកឱ្យជនក្រីក្រទៅ!"

(ម៉ាកុស ១០,១៧-៣០)

មនុស្សតែងចង់បានបុណ្យ ដោយប្រព្រឹត្តតាមវិន័យសាសនាដូចបុរសដែលមកគាល់ព្រះយេស៊ូ។ គាត់ជាមនុស្សល្អត្រឹមត្រូវ កាន់តាមវិន័យក្នុងគ្រប់វិស័យតាំងពីកុមារមក។ តើក្នុងចំណោមគ្រិស្តបរិស័ទយើងនរណាហ៊ាននិយាយអួតដូចគាត់បាន? អ្នកនោះគួរឱ្យព្រះយេស៊ូស្រឡាញ់ ព្រោះគាត់ជាអ្នកមានបុណ្យច្រើន។ តែព្រះអង្គបង្ហាញមាគ៌ាមួយផ្សេងទៀតដើម្បីឱ្យគាត់រួមរស់ជាមួយព្រះជាម្ចាស់ ឱ្យគាត់ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ និងឱ្យគាត់បានដូចព្រះអង្គ។ គាត់ត្រូវលះបង់អ្វីៗ ទាំងអស់ ដែលគាត់មានចែកឱ្យជនក្រីក្រ។ ត្រង់នេះព្រះយេស៊ូបានប្រៀនប្រដៅ ដូចព្រះពុទ្ធបរមគ្រូដែរ។ លោកទាំងពីរប្រៀនប្រដៅឱ្យលះបង់អ្វីៗ ទាំងអស់។ ដូច្នេះបងប្អូនដែលមានគ្រួសារ មានកូនចៅ ត្រូវតែគិតគូរដល់អនាគតគ្រួសារ និងអនាគតកូន ប៉ុន្តែត្រូវគិតគូរដល់ជនក្រីក្រដែរ កុំចង់បានទ្រព្យសម្បត្តិហួសពេក។ ខ្លួនក៏ត្រូវផ្ញើជីវិតលើព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ដែលថែរក្សាខ្លួនជានិច្ច។



ម្យ៉ាងទៀតអត្ថបទនេះគឺមានអត្ថន័យជ្រៅជាងទៅទៀត យើងត្រូវដឹងថា យើងមិនអាចសង្គ្រោះខ្លួនដោយខ្លួនឯង ឬដោយការសន្សំនូវកុសលផលបុណ្យទេ យើងទទួលនូវការសង្គ្រោះដោយមិនពឹងផ្អែកលើកុសលផលបុណ្យដែលយើងមាននោះទេ។ យើងទទួលនូវការសង្គ្រោះដោយផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូវិញ។ ត្រង់នេះ គ្រិស្តសាសនាគឺប្លែកពីពុទ្ធសាសនា។ យើង "ដើរតាមព្រះយេស៊ូ" គឺផ្ញើជីវិតទាំងស្រុងលើព្រះអង្គដោយមិនពឹងលើអ្វីផ្សេងទៀតឡើយ។



### ថ្ងៃទី ២២ តុលា ២០០៦ ត្រូវនឹងអាទិត្យទី ២៩ ប្រចាំឆ្នាំ "ខ"

## "អ្នកចង់ធ្វើមេគេ ត្រូវធ្វើទាសកររបស់គេគ្រប់គ្នា"

(ម៉ាកុស ១០,៣៥-៤៥)

ក្នុងព្រះសហគមន៍ ក៏ដូចជាក្នុងសង្គមធម្មតាដែរ គឺមនុស្សយើងចង់បានកិត្តិយស ចង់ឱ្យគេគោរព ឱ្យគេស្រលាញ់រាប់អាន។ នេះជាកិលេសតណ្ហាធម្មតានៃមនុស្ស។ សាវ័កទាំង១២នាក់ មានចិត្តលោភលន់។ ទាំងអស់គ្នាកុំស្មានថា មានតែ២នាក់ ប៉ុណ្ណោះនោះ! ព្រះយេស៊ូមានព្រះបន្ទូលលើកទី៣ថា ព្រះអង្គត្រូវរងទុក្ខ និងត្រូវគេធ្វើគុតយ៉ាងសែនអាម៉ាស់ រីឯពួកគេ សូមចង់បានកៅអីពិសេសក្នុងព្រះរាជ្យ! អស្ចារ្យមែន! លោកម៉ាកុសរៀបរាប់រឿងនេះ២ដង បានសេចក្ដីថា ការណ៍នេះសំខាន់ ក្នុងព្រះសហគមន៍ពីដើមក៏ដូចនៅក្នុងព្រះសហគមន៍យើងសព្វថ្ងៃដែរ។

គ្រិស្តបរិស័ទទោះមានមុខងារអ្វីក៏ដោយ ក្នុងព្រះសហគមន៍ក្ដី ឬក្នុងសង្គមក្ដី ឬក្នុងក្រុមគ្រួសារក្ដី ក៏ត្រូវមានទឹកចិត្តដូចព្រះយេស៊ូ ត្រូវរួមស្លាប់រួមរស់ជាមួយព្រះអង្គ។ យើងមិនអាចទាមទារអ្វីពីព្រះជាម្ចាស់សោះឡើយ គឺយើងគ្រាន់តែទទួលព្រះអំណោយទានពីព្រះអង្គប៉ុណ្ណោះ។

ប្រសិនបើក្នុងព្រះសហគមន៍ គ្រិស្តបរិស័ទមិនរកកិត្តិយស មិនរកប្រយោជន៍ផ្ទាល់ខ្លួនទេ ព្រះសហគមន៍



ពិតជាធ្វើសញ្ញាសម្គាល់អំពីរបៀបរស់នៅថ្មីក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់! បើមនុស្សទាំងអស់ប្រើអំណាចខ្លួនសម្រាប់បម្រើអ្នកដទៃ បម្រើប្រពន្ធកូន អ្នកជិតខាង និងប្រជាពលរដ្ឋទូទៅ នោះមុខជាកើតនូវសង្គមមនុស្សប្រកបដោយសេចក្ដីសុខសាន្ត និងសុភមង្គលដ៏ពិតប្រាកដជាពុំខានឡើយ!។

### ថ្ងៃទី ២៩ តុលា ២០០៦ ត្រូវនឹងអាទិត្យទី ៣០ ប្រចាំឆ្នាំ "ខ"

## "ព្រះគ្រូ! សូមប្រោសឱ្យភ្នែកខ្ញុំបានភ្លឺផង!"

(ម៉ាកុស ១០,៤៦ខ-៥២)

ព្រះយេស៊ូមានបន្ទូល៣ដងថា បន្តិចទៀតគេធ្វើបាបព្រះអង្គ គេនឹងធ្វើគុតព្រះអង្គយ៉ាងសែនអាម៉ាស់។ តែសាវ័កមិនយល់អ្វីសោះ។ គេចេះតែដណ្ដើមអំណាចគ្នា។ ក្នុងអត្ថបទនេះ ព្រះយេស៊ូធ្វើសញ្ញាសម្គាល់មួយ គឺព្រះអង្គប្រោសមនុស្សខ្វាក់ ឈ្មោះបាទីមេ ឱ្យបានភ្លឺ ទុកជានិមិត្តរូបបញ្ជាក់ថា មានតែព្រះយេស៊ូមួយព្រះអង្គគត់ដែលប្រទានជំនឿឱ្យមនុស្ស។

យើងទាំងអស់គ្នាប្រៀបដូចមនុស្សខ្វាក់ និងពិបាកយល់ថា ព្រះយេស៊ូសង្គ្រោះមនុស្សលោក ដោយព្រះអង្គរងទុក្ខលើឈើឆ្កាងដូចចោរព្រៃដែលត្រូវបណ្ដាសា។ ហេតុអ្វីព្រះបិតាពុំបានសង្គ្រោះព្រះអង្គឱ្យរួចពីស្លាប់?។ យើងក៏មិនសូវយល់ពីអត្ថន័យព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងជីវិតយើងដែរ។

ក្រុមសាវ័កដើរតាមព្រះយេស៊ូប្រកាសថា លោកយេស៊ូគឺជាព្យាការី ពីភូមិណាសារ៉ែត ប៉ុន្តែគេមិនស្គាល់ឋានៈដ៏ពិតប្រាកដរបស់ព្រះអង្គទេ។ រីឯអ្នកខ្វាក់វិញ ទោះបីជាគាត់មើលមិនឃើញក្ដី ក៏គាត់ប្រកាសថាព្រះយេស៊ូគឺជាព្រះគ្រិស្ត។ គាត់បានក្រោកឡើង ហើយគាត់បានទទួលនូវព្រះជន្មថ្មីដ៏រុងរឿងរួមជាមួយព្រះគ្រិស្ត និងដើរតាមព្រះយេស៊ូ តាមផ្លូវទៅឈើឆ្កាង! គាត់ស្ទុះឡើង គឺផ្ញើជីវិតទាំងស្រុងលើព្រះអង្គ



មិនពឹងលើរបៀបរស់នៅចាស់ទៀតឡើយ។

យើងជាគ្រិស្តបរិស័ទ ទោះយើងមានឋានៈជាអ្វីក៏ដោយ ក្នុងព្រះសហគមន៍ក្ដី ឬនៅទីណាក្ដី ក៏ត្រូវតែអង្វរព្រះយេស៊ូថា "ព្រះគ្រូ! សូមប្រោសឱ្យភ្នែកខ្ញុំបានភ្លឺផង! យើងខ្ញុំមិនអាចផ្ញើជីវិតលើព្រះអង្គដោយកម្លាំងខ្លួនឯង បានឡើយ! សូមបន្ថែមជំនឿឱ្យយើងខ្ញុំផង!"។

សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !



## ផ្លូវឆ្ពោះទៅរកពន្លឺ !

បើនិយាយអំពីពន្លឺ យើងតែងត្រូវការ និងចង់រស់នៅក្នុងពន្លឺដ៏ស្រទន់ និងភ្លឺថ្លាជានិច្ច។ នៅក្នុង អ្នកនាំសារ លេខនេះ យើងសូមលើកយកប្រធានបទមួយដើម្បីធ្វើការរិះគិតរួមគ្នា គឺការអប់រំសម្រាប់កុមារ ដែលជាទំពាំងស្នងឫស្សី ឬជាកម្លាំងពិសេសដើម្បីអភិវឌ្ឍសង្គម និងព្រះសហគមន៍ទៅថ្ងៃអនាគត។ កុមារមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលការអប់រំ ទោះបីជាស្ថិតក្នុងឋានៈណាក៏ដោយ សមដូចពាក្យស្លោកមួយពោលថា : "ការអប់រំគឺសម្រាប់ទាំងអស់គ្នា ហើយទាំងអស់គ្នាសម្រាប់ការអប់រំ"។

នៅទសវត្សរ៍ចុងក្រោយនេះ ក្រោយពីសង្គ្រាម និងការចាប់កំណើតសាជាថ្មីនៅកម្ពុជា ព្រះសហគមន៍បានផ្ដោត និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការចូលរួមក្នុងវិស័យអប់រំនេះដោយបង្កើតជាគ្រឹះស្ថាននានា សាលាចំណេះទូទៅ និងសាលាបច្ចេកទេសជាច្រើនទៀត ពិសេសសាលាមត្តេយ្យសម្រាប់ទទួលកុមារ និងកម្មវិធីផ្សេងៗទៀតដែលជួយគាំទ្រក្នុងការអប់រំដល់កុមារ និងជាការចូលរួមអភិវឌ្ឍន៍ធនធានមនុស្សរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ការសង់សាលារៀន និងកម្មវិធីដើម្បីជួយកុមារ ត្រូវការការចូលរួមពីឪពុកម្ដាយ និងអាណាព្យាបាលដែរ។ ការជំរុញ និងលើកទឹកចិត្តកុមារ គឺមានតែអាណាព្យាបាល និងឪពុកម្ដាយប៉ុណ្ណោះ ដែលមានឥទ្ធិពលធ្វើជាគំរូល្អដល់កុមារក្នុងការជំរុញឱ្យពួកគេមានចំណង់ក្នុងការស្វែងរកចំណេះដឹង។

ប្រទេសកម្ពុជាត្រូវការធនធានមនុស្សគ្រប់គ្រាន់ដើម្បីអភិវឌ្ឍន៍។ យើងត្រូវមានចំណេះដឹងពិតប្រាកដ និងខ្ពង់ខ្ពស់ទើបអាចចម្លងសង្គមកម្ពុជាយើងនេះឆ្ពោះទៅរកពន្លឺនៃការរីកចម្រើនយ៉ាងពិតប្រាកដនោះបាន។

អ្នកនាំសារ

# មហាសន្និបាតនៃបេសកកម្មរបស់ព្រះសហគមន៍កាតូលិកនៅទ្វីបអាស៊ី AMC

ព្រះសហគមន៍កាតូលិកតែងហៅខែតុលាថា “ជាខែនៃបេសកកម្មរបស់ព្រះសហគមន៍”។ ជាក់ស្តែងនៅឆ្នាំនេះ មានព្រឹត្តិការណ៍ដ៏សំខាន់សម្រាប់ព្រះសហគមន៍កាតូលិកនៅក្នុងទ្វីបអាស៊ី នោះគឺការធ្វើ “មហាសន្និបាតនៃបេសកកម្មព្រះសហគមន៍នៅទ្វីបអាស៊ី”។

មហាសន្និបាតនេះធ្វើនៅក្រុងឈៀងម៉ៃ ប្រទេសថៃ ចាប់ពីថ្ងៃទី១៨-២២ តុលា ឆ្នាំ២០០៦។ មហាសន្និបាតលើកដំបូងប្រារព្ធធ្វើឡើងនៅទីក្រុងម៉ានីលប្រទេសហ្វីលីពីននៅឆ្នាំ១៩៧៩។ ចំណែកមហាសន្និបាត លើកទី២នេះ គឺមានការឧបត្ថម្ភគាំទ្រពីក្រុមប្រឹក្សាក្រសួង ប្រកាសដំណឹងល្អ នៃបុរីវ៉ាទីកង់ និងពីក្រុមសាសនទូតកាតូលិក។

ការប្រារព្ធនូវ AMC នៅក្រុងឈៀងម៉ៃ លើកនេះ មានការចូលរួមពីគណៈប្រតិភូពីបណ្តាប្រទេសនានាទូទាំងទ្វីបអាស៊ី។ ប្រធានបទសំខាន់ក្នុងមហាសន្និបាតនេះគឺ : “ការរៀបរាប់អំពីជីវិតព្រះយេស៊ូនៅទ្វីបអាស៊ី” ដោយមានការចែករំលែកលើបទពិសោធន៍ នៃជំនឿរបស់ខ្លួន។ នៅទីក្រុងម៉ានីលនាឆ្នាំ១៩៧៩ មានអ្នកចូលរួមក្នុងមហាសន្និបាតជាច្រើនដូចជា បូជាចារ្យកាតូលិក ទេវវិទូ បេសកជនវិទូកាតូលិក និងគ្រិស្តបរិស័ទតិចតួចដែរ។ រីឯមហាសន្និបាតនៅឈៀងម៉ៃ ភាគច្រើន គឺមានការចូលរួមពីគ្រិស្តបរិស័ទ ហើយក៏មានបូជាចារ្យ និងបព្វជិតដែលនៅរួមជាមួយពួកគេផងដែរ។

ចំពោះព្រះសហគមន៍នៅប្រទេសកម្ពុជាយើងវិញនោះ មានសមាជិកចូលរួម ២៦នាក់ ក្នុងនាមភូមិភាគទាំងបី និងមាន១០នាក់ទៀត ជាអ្នកអង្កេតនូវរាល់សកម្មភាពនៅក្នុងមហាសន្និបាត។


Photo: S. Philong
សមាជិកនីងចូលរួម AMC នៅឈៀងម៉ៃ

គោលបំណងនៃមហាសន្និបាតគឺជួយគ្រិស្តបរិស័ទឱ្យមានការភ្ញាក់ខ្លួន និងឱ្យធ្វើជាគ្រិស្តទូត បំពេញបេសកកម្មប្រកាសដំណឹងល្អនៅក្នុងប្រទេស និងនៅក្នុងទ្វីបរបស់ពួកគេតាមរយៈការពង្រឹងអត្តសញ្ញាណខ្លួនជាគ្រិស្តបរិស័ទ ។

លោកអភិបាលអន់តូនី ប្រចាំភូមិភាគកំពង់ចាម ក៏មានប្រសាសន៍ថា : “អ្នកចូលរួមមហាសន្និបាតក្នុងនាម ព្រះសហគមន៍កម្ពុជា នឹងរៀបចំដោយខ្លួនឯងក្នុងការចូលរួមប្រកាសអំពីជីវិតរបស់ព្រះយេស៊ូឱ្យដល់ប្រជាជនកម្ពុជា រាប់លាននាក់ ដែលបើកចិត្តស្តាប់ដំណឹងល្អនៃព្រះយេស៊ូ”។

អតីតសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ អះអាងនៅឯមហាសន្និបាតនៃព្រះសហគមន៍ទ្វីបអាស៊ី កាលពីឆ្នាំ១៩៩៨ ថា : “ព្រះគ្រិស្តគឺចាប់កំណើតនៅក្នុងទ្វីបអាស៊ី” និងទោះបីគ្រិស្តបរិស័ទទាំងនោះគ្រាន់តែជាក្រុមតូចមួយដែលមាន១ ទៅ២% ក៏ដោយ តែជំនឿរបស់គ្រិស្តបរិស័ទ គឺមិនមែនមកពីបរទេសចូលមកនៅក្នុងទ្វីបអាស៊ីនេះទេ”។

AMC នេះ បានរៀបចំឡើង ដោយមានការលើកទឹកចិត្តព្រះសហគមន៍នៅទ្វីបអាស៊ី ឱ្យប្រារព្ធមហាសន្និបាត នៃបេសកកម្មព្រះសហគមន៍នៅទ្វីបអាស៊ីរៀងរាល់បួន ឬប្រាំឆ្នាំម្តង ដោយមានជួយជ្រោមជ្រែងពីអតីតសម្តេចប៉ាបយ៉ូហាន ប៉ូលទី២ តាំងពីមុនពេលដែលព្រះអង្គចូលទីវង្គតម្លេះ។ រីឯមហាសន្និបាត ដែលធ្លាប់ប្រារព្ធនៅឯអាម៉េរិកឡាទីន ទទួលបានជោគជ័យជាខ្លាំង និងបានផ្សព្វផ្សាយទូទាំងទ្វីបអាម៉េរិកទាំងមូលទៀតផង។

បើតាមពាក្យសំដីដ៏មានខ្លឹមសារនៃអតីតសម្តេចប៉ាបយ៉ូហាន ប៉ូល ទី២ ជូនចំពោះលោកបូជាចារ្យទាំងអស់កាលនៅទីក្រុងម៉ានីល ឆ្នាំ១៩៩៥ បានជំរុញឱ្យព្រះសហគមន៍កាតូលិកនៅអាស៊ីកាន់តែរឹងមាំ។ “នៅសហវត្សរ៍ដំបូងព្រះឈើឆ្កាងត្រូវបង្កើតឡើងនៅទ្វីបអឺរ៉ុប បន្ទាប់មក នៅអាម៉េរិក និងអាព្រិច។ យើងធ្វើអធិដ្ឋានក្នុងសហវត្សរ៍ថ្មីនេះ ហើយរួបរួមជំនឿឱ្យបានទទួលជោគជ័យក្នុងទ្វីបអាស៊ីដ៏ធំធេងល្វឹងល្វើយនេះ” “ប្រជាជនអាស៊ីកំពុងមានការស្រេកឃ្លានទឹកដើម្បីចិញ្ចឹមជីវិត។ ហេតុនេះ គឺមានតែព្រះយេស៊ូគ្រិស្តទេ ដែលអាចបំពេញនូវសេចក្តីត្រូវការនេះបាន”។

លោកឌីពុកអូមែរ ហ្គីរាល់ដូ

## តើហេតុអ្វីបានជាមានមហាសន្និបាតនៅទ្វីបអាស៊ីនេះ?

នៅឆ្នាំ១៩៧៧ មហាសន្និបាតលើកទី១ នៃបេសកកម្មព្រះសហគមន៍កាតូលិកបានប្រារព្ធនៅរដ្ឋម៉ិចស៊ិចកូ ដែលមានគណៈប្រតិភូមកពីបណ្តាប្រទេសអាម៉េរិកឡាទីនជាច្រើន។ ព្រះសហគមន៍កាតូលិកនៅទ្វីបអាម៉េរិកប្រារព្ធធ្វើមហាសន្និបាតនៃបេសកកម្មបានចំនួន ៧ លើកមកហើយ។ លើកទី៧ គឺនៅប្រទេសហ្គាតេម៉ាឡា Guatemala ទ្វីបអាម៉េរិកកណ្តាលឆ្នាំ២០០៣។ ព្រះសហគមន៍នៅទ្វីបអាស៊ីបានទទួលបទពិសោធន៍ជាច្រើនពីព្រះសហគមន៍នៅទ្វីបអាម៉េរិក និងបានចាប់ផ្តើមរៀបចំមហាសន្និបាតដោយខ្លួនឯង។





## អ្នកស្រីអ៊ុក ដារ៉ានី ហៅមឹង ទីន ១៣ឆ្នាំ ធ្វើការជាមួយអ្នកក្រីក្រ

អ្នកស្រីអ៊ុក ដារ៉ានី ជាគណៈកម្មការសង្គហៈទទួលខុសត្រូវភូមិភាគកំពង់ចាម ដែលស្ទើរតែរាល់ថ្ងៃត្រូវជួបទាក់ទងជាមួយអ្នកជំងឺក្រីក្រ និងដោះស្រាយបញ្ហារបស់ពួកគាត់អស់រយៈពេល ១៣ឆ្នាំកន្លងមកហើយ។ ខាងក្រោមនេះជាកិច្ចសម្ភាសន៍ជាមួយអ្នកស្រី ដែលលាលែងពីការងារនៅថ្ងៃទី១៥ តុលា ឆ្នាំ២០០៦ នេះ។

**អ្នកនាំសារ :** តាមរយៈការងារនេះ តើអ្នកស្រីជួបប្រទះទុក្ខលំបាកយ៉ាងដូចម្តេចខ្លះ ?

**អ៊ុក ដារ៉ានី :** ពេលខ្លះ យើងមានបញ្ហាជាមួយអ្នកជំងឺដែលមិនអាចព្យាបាលបាន និងស្លាប់។ បើគេជាគ្រិស្តបរិស័ទ យើងអញ្ជើញជូនដំ និងលោកបូជាចារ្យធ្វើពិធីតាមគ្រិស្តសាសនា។ បើជាពុទ្ធបរិស័ទក្រីក្រខ្លាំង យើងសុំមន្ទីរពេទ្យឱ្យយកសពទៅបូជានៅវត្តតាមប្រពៃណី។

**អ្នកនាំសារ :** រយៈពេល១៣ឆ្នាំនេះ តើព្រះសហគមន៍បានជួយអ្នកជំងឺប៉ុន្មាននាក់ និងចាយថវិកាប៉ុន្មាន ?

**អ៊ុក ដារ៉ានី :** ក្នុងរយៈពេល ១ឆ្នាំ យើងជួយអ្នកជំងឺប្រមាណជា ២៦០នាក់ ដូច្នេះបើគិតរយៈពេល ១១ឆ្នាំដែលខ្ញុំធ្វើការច្បាស់លាស់យើងជួយបាន ២៨៦០នាក់។ ថវិកាគឺចំណាយក្នុងមួយឆ្នាំ ប្រមាណជា ៥៤០០$។

**អ្នកនាំសារ :** តើការងារនេះមានទំនាក់ទំនងយ៉ាងណាដែរចំពោះជំនឿជាគ្រិស្តបរិស័ទ ?

**អ៊ុក ដារ៉ានី :** សម្រាប់ខ្ញុំជាគ្រិស្តបរិស័ទ ព្រះបន្ទូលជួយដាស់តឿន និងកែប្រែចិត្តគំនិតបន្តិចម្តងៗ ឱ្យខ្ញុំចេះអត់ធ្មត់ និងដាក់ខ្លួនដើម្បីទាក់ទងជាមួយអ្នកជំងឺក្រីក្រ។ ជំនឿបានកែប្រែជីវិតខ្ញុំឱ្យចេះតស៊ូក្នុងកិច្ចការងារនេះ។

រ៉ូ បូរ៉ា


Photo: Bora
អ្នកស្រីអ៊ុក ដារ៉ានី ហៅមឹង ទីន


Photo: L. Sovanna
ព្រះវិហារអ្នកលឿងនៃភូមិភាគកំពង់ចាមសព្វថ្ងៃ

## ស្ថិតិគ្រិស្តបរិស័ទនៃភូមិភាគកំពង់ចាម

តាមស្ថិតិដែលស្រង់ចេញពីអង្គសន្និបាតឆ្នាំ២០០៦ នេះ ចំនួនគ្រិស្តបរិស័ទ ព្រះសហគមន៍កំពង់ចាម មានដូចតទៅ:

ព្រះសហគមន៍កោះរពៅ មានគ្រិស្តបរិស័ទសរុបចំនួន ២២៥នាក់។ ព្រះសហគមន៍កាទិល គ្រិស្តបរិស័ទសរុបចំនួន ៣០នាក់។ ព្រះសហគមន៍ស្ទឹងត្រែង គ្រិស្តបរិស័ទចំនួន ៣៦នាក់ និងអ្នកស្វែងរកចំនួន ៩នាក់។ ព្រះសហគមន៍រតនគីរី គ្រិស្តបរិស័ទចំនួន ១៨នាក់ និងអ្នកស្វែងរកចំនួន ៥នាក់។ ព្រះសហគមន៍កំពង់ចាម គ្រិស្តបរិស័ទ ៦៧នាក់ ជំហានទី១ ១១នាក់ និងស្វែងរក ៥២នាក់។ ព្រះសហគមន៍ភូមិថ្មី គ្រិស្តបរិស័ទបរិស័ទ ១៤នាក់ ជំហានទី១ ម្នាក់ និងស្វែងរក ៤៩នាក់។ ព្រះសហគមន៍កោះរកា គ្រិស្តបរិស័ទ ១៦នាក់ ជំហានទី១ ១០នាក់ និងស្វែងរក ៥១នាក់។ ព្រះសហគមន៍ព្រៃវែង គ្រិស្តបរិស័ទ ២០នាក់ និងស្វែងរកចំនួន ៣០នាក់។ ព្រះសហគមន៍អ្នកលឿង គ្រិស្តបរិស័ទ ១៦០០នាក់។ ព្រះសហគមន៍ស្វាយរៀង ៧០នាក់។ ព្រះសហគមន៍ចម្លាក់ គ្រិស្តបរិស័ទ ២០នាក់ និងស្វែងរក ២០នាក់។ ព្រះសហគមន៍កអណ្តើក គ្រិស្តបរិស័ទម្នាក់ ជំហានទី១ ២៤នាក់ និងស្វែងរក ៣០នាក់។ ព្រះសហគមន៍ក្តុលលើ គ្រិស្តបរិស័ទ ៧០នាក់ ជំហានទី១ ម្នាក់ និងស្វែងរក ៥១នាក់។ ព្រះសហគមន៍ឆ្លូង គ្រិស្តបរិស័ទ ២៥នាក់។ ព្រះសហគមន៍ព្រែកក្របៅ គ្រិ ១៣០នាក់។ ព្រះសហគមន៍ ព្រែកពោធិ៍ គ្រិ ៧០នាក់។ ព្រះសហគមន៍សួង គ្រិ ៥នាក់ ជំហានទី១ ៤នាក់ និងស្វែងរក ២០នាក់។ ព្រះសហគមន៍ថ្មពេជ្រ គ្រិ ៨នាក់ ជំហានទី១ ៨នាក់ និងស្វែងរក ១០នាក់។ ប៊ូស្រា គ្រិ ១៩៤នាក់ និងស្វែងរក ៥៤នាក់។ ដាក់ដាំ គ្រិ ៣នាក់ និងស្វែងរក ៣០នាក់។ ត្រពាំងកណ្តោល គ្រិ ១៥នាក់ និងស្វែងរក ៣០នាក់។

លី សុវណ្ណា

**ការសិក្សាគឺជាផ្នែកមួយដ៏សំខាន់សម្រាប់មនុស្សម្នាក់ៗ ដែលរស់នៅគ្រប់ទីកន្លែង និងគ្រប់ប្រទេសលើសកលលោក។ កុមារាកុមារីជាវ័យមួយ ដែលត្រូវការទទួលនូវចំណេះដឹង និងការអប់រំទាំងនៅសង្គមខាងក្រៅ និងខាងក្នុងសង្គមគ្រួសារ។ ការជំរុញកូនៗ ឱ្យទៅសាលា គឺជាភារកិច្ចដ៏ទៀងទាត់របស់ឪពុកម្តាយ ហើយចំពោះកូនៗ ក៏មិនមែនរង់ចាំតែការដាស់តឿនរបស់ឪពុកម្តាយដែរ។ ការភ្ញាក់រលឹកដោយខ្លួនឯង គឺជាគំរូមួយដ៏ប្រសើរបំផុតសម្រាប់ក្មេងៗ។ តើឪពុកម្តាយត្រូវយកចិត្តទុកដាក់យ៉ាងណាចំពោះការជំរុញកូនទៅសាលារៀន? តើកុមារាកុមារីដែលជាកូនៗត្រូវធ្វើយ៉ាងណាដែរចំពោះការសិក្សារបស់ខ្លួន?**

# ឪពុកម្តាយជាមាគ៌ានាំកូនទៅរកការអប់រំ



Photo: P. Samphy

ការសិក្សាធ្វើឱ្យកុមារាកុមារីមានកំណប់ទ្រព្យដែលមិនចេះរីងស្ងួតសម្រាប់ចាយវាយ និងប្រើប្រាស់នៅថ្ងៃអនាគត



Photo: K. Kagha

បើសិនប្រិយមិត្តទាំងឡាយមានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាអំពីអត្ថបទនេះ សូមផ្ញើសំបុត្រមកកាន់ការិយាល័យព្រឹត្តិបត្រ "អ្នកនាំសារ" តាមរយៈលោកឪពុក បងប្រុស-បងស្រីដែលនៅជិតបំផុត។

"ម៉ែៗ កូនអាយុ៦ឆ្នាំហើយ។ ហើយវាយ៉ាងម៉េចកូន?។ កូនគ្រប់អាយុចុះឈ្មោះចូលរៀនហើយ។ ហ៊ឺ! ម៉ែមិនដឹងទេ សួរពុកកូនទៅ។ ហ៊ឺ! ពុកគ្មានលុយទេ ចាំពុកមានលុយសិន ..."។ នេះជាបទសន្ទនាខ្លីមួយ ដែលមានផ្សាយជារៀងរាល់ថ្ងៃ តាមរយៈកញ្ចក់ទូរទស្សន៍ និងស្ថានីយវិទ្យុនានា។ ស្ប៉ុតខ្លីនេះគឺចង់បង្ហាញដល់អ្នកទស្សនាទាំងអស់ ជាពិសេសឪពុកម្តាយ ឱ្យភ្ញាក់រលឹកនឹកនាំកូនទៅសាលារៀន។ បច្ចុប្បន្ននេះ ក្មេងៗទាំងប្រុសទាំងស្រី បានទទួលនូវការអប់រំស្ទើរតែទាំងអស់បើប្រៀបធៀបទៅនឹងប៉ុន្មានឆ្នាំមុនៗ។ ប៉ុន្តែក៏នៅមានកុមារមួយចំនួនតូចមិនបានទៅសាលាព្រោះរវល់នឹងការងារចិញ្ចឹមជីវិត ឬក៏ជួយសំរាលជីវភាពឪពុកម្តាយពួកគេ។

នៅដើមខែតុលានេះ សិស្សៗនៅតាមសាលានានា គ្រប់ខេត្តក្រុង ទូទាំងប្រទេសកម្ពុជា បានប្រារព្ធធ្វើទិវា បវេសនកាលនាឆ្នាំសិក្សា២០០៦-២០០៧។ កំពុងតែធ្វើពលកម្មសំអាតទីធ្លានៅក្នុងវិទ្យាល័យ ១ឧសភា ស្ថិតក្នុងខេត្តតាកែវ ដើម្បីត្រៀមលក្ខណៈក្នុងការចូលរៀនថ្នាក់ថ្មី និងជួបមិត្តភក្តិថ្មី ជាពិសេស គឺគ្រូបង្រៀនថ្មី កុមារីឌុយ បញ្ញា និងសិស្សានុសិស្សជាច្រើនទៀតជុំវិញខ្លួននាង កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងការសំអាតថ្នាក់រៀនថ្មី។ ញើសហូរកាត់ថ្ពាល់បណ្តាក់គ្នាមិនដាច់ និងឋិតនៅក្រោមពន្លឺថ្ងៃ បញ្ញាដែលទើបប្រលងជាប់ថ្នាក់ឌីប្លូមថ្មីៗនិយាយថា នាងរីករាយខ្លាំងណាស់ដោយបានចូលរៀនថ្នាក់ថ្មី។ រួមនឹងសម្លេងសើចហាក់ដូចជា អៀនបន្តិច កុមារីតូចនេះ បន្តទៀតថា: "ពេលខ្លះខ្ញុំមានការខ្ជិលរៀនដែរ តែធ្វើម៉េចបើនេះជាភារកិច្ចខ្ញុំ ដែលឪពុកម្តាយឱ្យមករៀន តែម៉ាក់របស់ខ្ញុំពុំដែលបង្ខំខ្ញុំ ឱ្យរៀនខ្លាំងពេកនោះដែរ ប៉ុន្តែគាត់តែងតែលើកទឹកចិត្តខ្ញុំ ដោយការផ្តល់ជាថវិកា ឬទិញកាដូឱ្យ បើខ្ញុំរៀនបានចំណាត់ថ្នាក់ល្អ"។ អ្នកស្រីសុខា ត្រូវជាម្តាយបញ្ញា មានប្រសាសន៍ថា: "ការសិក្សារបស់កូនពិតជាសំខាន់ណាស់។ ខ្ញុំគ្មានអ្វីឱ្យវាក្រៅអំពីចំណេះវិជ្ជានេះទេ។ នៅពេលមានចំណេះដឹងហើយ ពួកគេអាចរកការងារបានយ៉ាងស្រួល និងមិនបាច់រកស៊ីលំបាកដូចខ្ញុំទៀត"។

ចំណែកអ្នកស្រីជ មុំ អាយុ ៣២ឆ្នាំ មានប្រសាសន៍ដែរថា: "ក្នុងនាមយើងជាឪពុកម្តាយ នៅពេលដែលកូនៗ ដល់អាយុត្រូវចូលរៀន យើងត្រូវជំរុញពួកគេឱ្យទៅសាលា"។ ស្ត្រីជាម្តាយកូន២រូបនេះ បន្តថា គាត់ចង់ឱ្យកូនខិតខំរៀនសូត្រ តែគាត់មិនដែលបង្ខិតបង្ខំកូនខ្លាំងពេកនោះដែរ"។

កំពុងរត់ប្រលែងគ្នាលេងនៅជិតម្តាយ កុមារីដ៏ស្រស់សោភា និងចេះគួរសមគោរពចាស់ទុំ សម្បត្តិ វរ៉ានីតា អាយុ ១០ឆ្នាំ បានងាកមកអង្គុយយ៉ាងមានសណ្តាប់ធ្នាប់ ហើយបានឱ្យដឹងថា នាងរៀនថ្នាក់ទី៤ នៃបឋមសិក្សាវឌ្ឍនវិជ្ជានៅក្នុងទីក្រុងភ្នំពេញ។ វរ៉ានីតា បន្ថែមទៀតថា: "ការសិក្សា គឺមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំព្រោះនៅពេលរៀនចប់ ខ្ញុំអាចស្វែងរកការងារបានធ្វើល្អ និងមានអនាគតល្អ"។ នៅក្នុងមួយថ្ងៃ វរ៉ានីតាចំណាយពេលរៀននៅសាលារដ្ឋ ៤ម៉ោង និងនៅផ្ទះ នាងក៏រៀនបន្ថែមប្រមាណជា ២-៣ម៉ោងទៀត ដែលពេលខ្លះ នាងរៀនដោយខ្លួនឯង ឬក៏មានបងប្រុសជួយបង្រៀន។ ត្រង់ចំនុចនេះនាង ហាក់ដូចជាមានការអន់ចិត្តបន្តិច ដោយនាងនិយាយថា បើយើងមិនខិតខំរៀនបន្ថែមនៅផ្ទះទេនោះ យើងមិនអាចរៀនឆាប់ចេះទេ ពីព្រោះការសិក្សានៅសាលារដ្ឋ នាងមានការពិបាកខ្លះៗ ដោយសារគ្រូមួយចំនួន មិនសូវជាយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្ស។

"ការសិក្សារបស់កូនមានសារសំខាន់ណាស់សម្រាប់អនាគតគេទៅថ្ងៃខាងមុខ។ ហើយក្នុងនាមយើងដែលជាឪពុកម្តាយ យើងតែងតែដាស់តឿនឱ្យកូនខិតខំរៀនសូត្រដើម្បីអនាគតល្អ និងពន្យល់រាល់ហេតុផលផ្សេងៗ ដែលកើតមាននៅក្នុងសង្គម ដែលសង្គមជាតិត្រូវការតែអ្នកចេះ។ ប្រសិនជាយើងមិនចេះអ្វីនោះទេ នៅពេលអនាគតយើងពុំអាចរកការងារល្អធ្វើនឹងគេឡើយ"។ នេះជាសំដីរបស់អ្នកស្រីមុំ ដែលគាត់តែងនិយាយប្រាប់ដល់កូនៗរបស់គាត់។ "ខ្ញុំមិនខឹងនឹងម៉ាក់របស់ខ្ញុំទេ ពីព្រោះការប្រៀនប្រដៅរបស់គាត់តែងតែចង់ឱ្យកូនល្អ" សំឡេងគ្រលួចដ៏មុតមាំនេះ បានបន្លឺឡើងពីអណ្តាតរបស់សម្បត្តិ វរ៉ានីតា។ មិនតែប៉ុណ្ណោះ នាងក៏មិនដែលមានអារម្មណ៍ធុញទ្រាន់នឹងការសិក្សាដែរ ហើយអ្វីដែលអស្ចារ្យនោះ នៅពេលរៀនចប់ នាងចង់ធ្វើជារដ្ឋមន្ត្រីស្រី ព្រោះនាងចង់ឱ្យគេហៅថា លោកជំទាវ។

លោកសុធា គឺជាឪពុកមួយរូប ដែលមានការទទួលខុសត្រូវ និងយកចិត្តទុកដាក់ចំពោះកូនស្រីរបស់លោកជាខ្លាំង។ ទោះបីលោកប្រកបរបរ គ្រាន់តែជាគ្រូទាយក៏ដោយ ប៉ុន្តែលោកនៅខិតខំតស៊ូដើម្បីកូនគាត់ជានិច្ច ដោយគាត់មិនខ្លាចនឿយហត់ក្នុងការរកលុយមកផ្គត់ផ្គង់ការសិក្សារបស់កូនឡើយ។ លោកក៏ប្រាប់ឱ្យដឹងថា: "ទោះបីជាខ្ញុំត្រូវចំណាយអស់ប្រាក់ប៉ុន្មាន ក៏ខ្ញុំអាចរកវាបានសម្រាប់ការសិក្សារបស់កូនខ្ញុំដែរ។ ខ្ញុំចង់ឱ្យវារៀនបានខ្ពង់ខ្ពស់នឹងគេ"។

## ការអប់រំសម្រាប់អ្នកគ្រប់គ្នានៅក្នុងជីវិត

បើយោងតាមឯកសារនៃអង្គការយូណេស្កូបានឱ្យដឹងថា កិច្ចអភិវឌ្ឍន៍សំខាន់ៗ បានកើនឡើង នាពេលថ្មីៗនេះ គឺនៅក្នុងផ្នែកអប់រំនៅក្នុងប្រទេសកម្ពុជា។ ក្រសួងអប់រំយុវជន និងកីឡា កំពុងអនុវត្តលើដំណើរការនៃទម្រង់ដ៏សំខាន់ ទៅលើសេវាអប់រំសិក្សាក្នុងប្រទេស និងក៏មាននូវចំណាប់អារម្មណ៍ដែលចេះតែកើនឡើងជាលំដាប់នៃដៃគូនៅក្នុងចំណោមអ្នកចូលរួមដ៏សំខាន់ៗ និងម្ចាស់ជំនួយបានបង្ហាញពីគោលបំណងដើម្បីត្រួសត្រាយនូវកិច្ចគាំទ្របន្ថែមទៀតដល់ ក្រសួងអប់រំយុវជន និងកីឡា។ ទោះបីជាយ៉ាងណាក៏ដោយ វិស័យអប់រំនៅតែស្ថិតក្រោមការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារដំណើរការយឺតយ៉ាវ លើកំណែទម្រង់សំខាន់ៗដទៃទៀត។ ក្នុងឆ្នាំ ២០០១ គឺមានការកើនឡើងយ៉ាងខ្លាំងក្លា លើការចុះឈ្មោះចូលរៀនរបស់កុមារាកុមារី ដែលវាមានការកើនឡើងរហូតដល់ ១៤ % ក្នុងកម្រិតបឋមសិក្សា ១៩%ក្នុងមធ្យមសិក្សា និង២៣% ជាការកើនឡើងនៃចំនួនសិស្សស្ត្រី រៀនថ្នាក់ទី៦ រវាងឆ្នាំ២០០០-២០០១និងឆ្នាំ២០០១-២០០២។ ទន្ទឹមគ្នានឹងកំណើននេះ នៅមានសិស្ស ដែលគ្រប់អាយុចូលរៀនបឋមសិក្សាប្រមាណជា ៣៥០០០០នាក់ នៅតែមិនទាន់បាន...

### សរសេរអនាគតឡើងវិញ?

ជាគម្រោងយុទ្ធនាការជាសកលរបស់អង្គការសង្គ្រោះកុមារដើម្បីនាំមកនូវគុណភាពល្អលើការអប់រំដល់កុមារដែលរស់នៅក្នុងតំបន់ដែលទទួលផលប៉ះពាល់ដោយសង្គ្រាម។ បច្ចុប្បន្ននេះ កុមារជាង ១០០លាននាក់ក្នុងពិភពលោកកំពុងមិនបានទទួលការអប់រំ និងកុមារចំនួនជាង ៥០ លាននាក់កំពុងរស់នៅក្នុងតំបន់ទទួលការប៉ះពាល់ដោយសារតែសង្គ្រាម។

... ចូលរៀន។ ការប្តេជ្ញាត្រូវបានគេត្រូវការយ៉ាងបន្ទាន់ ប្រសិនបើការអប់រំ សម្រាប់អ្នកគ្រប់គ្នា និងការអប់រំអក្ខរកម្មដល់មនុស្ស ដែលមានអាយុពី១៥-២៤ឆ្នាំ ត្រូវបានគេចង់ធ្វើឱ្យសម្រេចជាគោលដៅ។ ការអប់រំកម្រិតបឋមសិក្សាជាផ្នែកមួយដ៏សំខាន់ បន្ទាប់ពីផ្នែកធំនៃប្រព័ន្ធអប់រំ និងផ្តល់ឱកាសតែមួយគត់ ដើម្បីចូលរួមលើដំណើរការនៃការកែប្រែសង្គមតាមរយៈការអប់រំក្មេងៗ។ ចាប់តាំងពីមានសន្និសីទអំពីការអប់រំសម្រាប់ជនគ្រប់ៗរូប ទូទាំងពិភពលោក ដែលប្រព្រឹត្តទៅ ក្នុងឆ្នាំ១៩៩០ នៅឯប្រទេសថៃ ការចុះឈ្មោះចូលរៀនរបស់កុមារមានការកើនឡើងយ៉ាងខ្លាំងក្លា។

### ច្បាប់អប់រំ

គំនិតផ្តើមកែទម្រង់របស់ ក្រសួងអប់រំយុវជន និងកីឡា ក្នុងបរិបទនៃកម្មវិធីគាំទ្រវិស័យអប់រំ និងការអប់រំសម្រាប់ទាំងអស់គ្នានឹងត្រូវបានគាំទ្រ និងពង្រីកបន្ថែមតាមរយៈការអភិវឌ្ឍន៍ច្បាប់ និងបទដ្ឋានអប់រំ។ ច្បាប់រដ្ឋធម្មនុញ្ញនៃកម្ពុជាកំនត់ឱ្យអប់រំដោយពុំបង់ថ្លៃរយៈពេល ៩ឆ្នាំ នៅសាលារដ្ឋ។ ការអភិវឌ្ឍន៍នូវច្បាប់អប់រំ ដែលមានវិសាលភាពធំទូលាយនឹងបង្កើតឱ្យមាននូវបទដ្ឋាន និងច្បាប់ដែលមានឆន្ទះច្បាស់លាស់ ដើម្បីអនុវត្តច្បាប់រដ្ឋធម្មនុញ្ញ ដែលអាចធានាបាននូវគុណភាព និងសេវាអប់រំនៅគ្រប់កម្រិតទាំងអស់។

ច្បាប់អប់រំបានកំណត់ស្តង់ដា ដែលស្របគ្នាទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ដែលកម្ពុជាជារដ្ឋភាគីមួយក្នុងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ និងអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់រូបភាពរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីបន្ថយគំលាតនៃវប្បធម៌ យេនឌ័រ សង្គម និងភូមិសាស្ត្រផងដែរ។ ច្បាប់អប់រំនឹងជាគម្រោងណែនាំដើម្បីគាំទ្រនូវកំណែទម្រង់អប់រំដោយបញ្ជាក់ពីអាណត្តិ តួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋានទាំងអស់ក្រោមឱវាទ ក្រសួងអប់រំយុវជន និងកីឡា។

លើសពីនេះទៅទៀត ច្បាប់អប់រំនឹងលើកកម្ពស់នូវគំនិតផ្តួចផ្តើមគោលនយោបាយអភិបាលកិច្ច ដូចជា វិមជ្ឈការកម្មវិធីសិក្សា ថវិកា និងការចូលរួមពីគ្រប់ភាគីទាំងអស់ដោយមានការរួមបញ្ចូលទាំងមាតាបិតា និងសហគមន៍នៅក្នុងការគ្រប់គ្រងអប់រំលើកកម្ពស់ភាពទន់ភ្លន់ និងទទួលខុសត្រូវនៅក្នុងប្រព័ន្ធអប់រំ (ច្បាប់អប់រំដកស្រង់ពីកាសែតរស្មីកម្ពុជា)។

### តាមអង្គការសហប្រជាជាតិ

ក្មេងៗប្រមាណជាង ៨០% បានចូលរៀន។ ការប្រឹងប្រែងដែលសំខាន់ គឺដើម្បីធានានូវការទទួលបានការសិក្សាស្មើៗគ្នា ក្នុងកម្រិតអប់រំមូលដ្ឋាន ការបង្កើននូវថវិកាឧបត្ថម្ភទៅលើមធ្យោបាយធ្វើដំណើរ និងអាហារូបករណ៍ទៅដល់សិស្សមកពីគ្រួសារក្រីក្រ ហើយនិងបង្កើននូវគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធបង្រៀន។

## លោកហ្គាប៊ី : “វិន័យរបស់ខ្ញុំ គឺអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ”


Photo: DR

ទាក់ទងនឹងការយកចិត្តទុកដាក់ដល់ការអប់រំក្មេងៗ ក្នុងព្រះសហគមន៍ អ្នកនាំសារ បានជួបសម្ភាសន៍ជាមួយលោកបូជាចារ្យហ្គាប៊ី អ្នកទទួលបន្ទុកថែរក្សាក្មេងៗ នៅមណ្ឌលអារ៉ុបពេ (បាត់ដំបង) ក្នុងខ្លឹមសារដូចតទៅ :

**អ្នកនាំសារ :** ព្រះសហគមន៍បាត់ដំបងមានសកម្មភាពអ្វីជាមួយក្មេងៗ ?

**បូជាចារ្យហ្គាប៊ី :** យើងជួយក្មេងពីរយ៉ាង ទី១ ជួយពួកគេឱ្យស្នាក់នៅមណ្ឌលអារ៉ុបពេ បានរៀនសូត្រពីសីលធម៌ បញ្ហាសុខភាព និងផ្តល់សម្លៀកបំពាក់ សៀវភៅ និងសម្ភារៈជាច្រើនទៀត។ ទី២ ជួយក្មេងៗតាមផ្ទះដែលមានឪពុកម្តាយមានជីវភាពគ្រាន់បើ។ យើងជួយជាសម្លៀកបំពាក់ សៀវភៅ ប៊ិច ថវិកាខ្លះសម្រាប់រៀនភាសា និងឱ្យកង់ដល់អ្នកមានផ្ទះឆ្ងាយពីសាលារៀន។

**អ្នកនាំសារ :** តើហេតុអ្វីបានជាព្រះសហគមន៍ជួយដល់ពួកគេ ?

**បូជាចារ្យហ្គាប៊ី :** យើងជួយពួកគេ ព្រោះយើងជាគ្រិស្តបរិស័ទចេះស្រលាញ់គ្នា និងជួយគ្នាទៅវិញទៅមក។ យើងធ្វើតាមព្រះបន្ទូលព្រះយេស៊ូដែលថា : “វិន័យរបស់ខ្ញុំគឺអ្នករាល់គ្នាស្រលាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ”។ មួយទៀតយើងផ្តល់ឱកាសដល់ពួកគេឱ្យបានរៀនសូត្រដើម្បីរីកចម្រើនក្លាយជាមនុស្សល្អ មានអនាគតល្អ និងបង្ហាត់ឱ្យពួកគេចេះស្រលាញ់គ្នាទៅវិញទៅមក។

**អ្នកនាំសារ :** បើមិនទទួលការអប់រំ តើពួកគេនឹងទៅជាយ៉ាងណា ?

**បូជាចារ្យហ្គាប៊ី :** អត់ស្រួលទេ ! បើពួកគេគ្មានចំនេះដឹង គេមិនអាចរកស៊ីបានជោគជ័យ ពិសេសគេជាអ្នកស្រែពុំច្បាស់លាស់សម្រាប់អនាគត។ ប៉ុន្តែមានមនុស្សមួយចំនួនតូចមិនបានរៀនសូត្រ ឬទទួលការអប់រំតែពួកគេឆ្លាតអាចរកស៊ីបាន ដោយសារគេមានខួរក្បាលល្អ។

**អ្នកនាំសារ :** តើការអប់រំមានសារៈសំខាន់យ៉ាងណាចំពោះពួកគេ ?

**បូជាចារ្យហ្គាប៊ី :** មនុស្សជាច្រើនរៀនចប់ថ្នាក់ទី១២ ឬមហាវិទ្យាល័យ ហើយគេគិតយ៉ាងណាឱ្យខ្លួនឯងមានចំណេះដឹង ការងារល្អ រកស៊ីស្រួល និងមានគ្រួសារល្អ។ ប៉ុន្តែសម្រាប់ខ្ញុំការអប់រំសំខាន់ណាស់ ព្រោះវាធ្វើឱ្យគំនិតមានកាន់តែច្រើនឡើងៗ និងមានប្រាជ្ញាល្អសម្រាប់ជួយសង្គម។

អត្ថបទដោយមុំ គន្ធា និងសុជាតិ





បន្ទាប់ពីចាប់កំណើតក្រោយពីសង្គ្រាមបំផ្លិចបំផ្លាញស្ទើរទាំងស្រុង ព្រះសហគមន៍បានខិតខំពង្រឹងជំនឿ និងសកម្មភាពរបស់ខ្លួនដោយចូលរួមយ៉ាងជិតស្និទ្ធជាមួយប្រជាជន។ ការអប់រំចំណេះទូទៅដល់កុមារ និងយុវជនគឺជាភារកិច្ចអាទិភាពមួយ។

# ពិធីបិទវគ្គបំប៉នកុមារ នៅភូមិប៉ាង


Photo: L. Sovanna

ក្រុមប្អូនៗកុមាររាំរបាំព្រាបសន្តិភាពនៅក្នុងកម្មវិធីបិទវគ្គបំប៉នការសិក្សាដល់កុមារ

ក្នុងកម្មវិធីវគ្គអប់រំបំប៉ន ដល់កុមារា កុមារី ឱ្យចេះអាន ចេះសរសេរអក្សរខ្មែរ និងការអប់រំសីលធម៌ បានប្រារព្ធពិធីបិទវគ្គរបស់ខ្លួនកាលពីថ្ងៃទី១៤ កញ្ញា ឆ្នាំ២០០៦ កន្លងទៅនេះ បន្ទាប់ពីបានបំពេញសកម្មភាពរបស់ខ្លួន អស់រយៈពេល២ខែ មកនៅក្នុងព្រះសហគមន៍ភូមិប៉ាង ឃុំច្រនៀង ស្រុងបារាយណ៍ ខេត្តកំពង់ធំ នៃភូមិភាគបាត់ដំបង។

កម្មវិធីមានការចូលរួមពីសំណាក់លោកមេភូមិ លោកបូជា-ចារ្យទទួលខុសត្រូវ បងស្រី អាណាព្យាបាល លោក-អ្នកគ្រូស្ម័គ្រចិត្ត និងសិស្សានុសិស្សប្រមាណជា ១៥០នាក់។ តាមរបាយការណ៍ដែលអានដោយអ្នកគ្រូហេង ហួយ បានបង្ហាញថា កម្មវិធីវគ្គអប់រំបំប៉នការអាន និងសរសេរភាសាខ្មែរដល់កុមារាកុមារីនេះបានដំណើរការចំនួន ៤វគ្គហើយ។ ក្នុងមួយវគ្គៗមានរយៈពេល២ខែ គឺនៅពេលវិស្សមកាលរបស់សិស្សពីការរៀនសូត្រនៅសាលារដ្ឋ ហើយនៅក្នុងវគ្គទី៤នេះមានសិស្សចូលរួមទាំងអស់ចំនួន ១១៣នាក់ ដែលមាន ៤កម្រិតចាប់ពីមត្តេយ្យដល់ថ្នាក់ទី៣។ លោកបូជាចារ្យហ្វ្រង់កូ គឺជាអ្នកទទួលខុសត្រូវក្នុងព្រះសហគមន៍នេះ បានពន្យល់ឱ្យដឹងអំពីមូលហេតុចម្បង ដែលនាំឱ្យមានកម្មវិធីនេះឡើង យ៉ាងដូច្នេះថា : “ក្មេងនៅទីនេះ គេចង់រៀន និងយកចិត្តទុកដាក់ចំពោះការសិក្សាណាស់ ប៉ុន្តែដោយទីតាំងភូមិសាស្ត្រមិនបានអំណោយផលដោយភូមិនេះនៅជនបទដាច់ស្រយាលឆ្ងាយពីសាលារៀន ហើយការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ក៏ពុំជិតដល់ ដែលនាំឱ្យក្មេងគ្មានការរីកចម្រើន និងគ្មានឱកាសរៀនផងដែរ”។ លោកបូជាចារ្យបានបង្ហាញនូវសុទិដ្ឋិនិយមថា ទោះបីកម្មវិធីនេះមានរយៈពេលខ្លី ប៉ុន្តែវាក៏បានផ្តល់ឱ្យក្មេងយល់ពីតម្លៃ ចូលចិត្តការសិក្សា និងមានទម្លាប់ក្នុងការអានសៀវភៅនៅពេលទំនេរ។ បើភូមិនេះ មានអ្នកចេះដឹងច្រើនច្បាស់ជានឹងបានរីកចម្រើន។ កញ្ញាវីដា មានអាយុ ១៩ឆ្នាំ និងជាគ្រូស្ម័គ្រចិត្ត បង្ហាញពីអារម្មណ៍ខ្លួនថា ការបង្រៀនរបស់នាងនៅភូមិនេះ មានតម្លៃណាស់ គឺវាជួយឱ្យក្មេងចេះអាន និងសរសេរច្បាស់លាស់។ នាងបន្តដែរថា ការចេះអានចេះសរសេរអក្សរ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះសង្គមយើងសព្វថ្ងៃ ត្រូវការអ្នកចេះដឹងដើម្បីធ្វើការអភិវឌ្ឍន៍។

ចំណែកលោកសុខ ជាមេភូមិ បានកោតសរសើរចំពោះប្អូនៗសិស្សានុសិស្ស ដែលខិតខំ និងយកចិត្តទុកដាក់សិក្សាព្រមៗគ្នា។ លោកសង្កត់ធ្ងន់ថា : “វាជាសារៈសំខាន់ក្នុងការសិក្សាពីអក្សរសាស្ត្រខ្មែរ របាំប្រពៃណី និងពីសីលធម៌រស់នៅ ពី-ព្រោះយើងជាខ្មែរ ត្រូវតែចេះ និងស្គាល់”។ លោកក៏ធ្វើការផ្តាំផ្ញើដល់អាណាព្យាបាល ឱ្យជួយជំរុញអប់រំកូនចៅបានទៅរៀនសូត្រទាំងអស់គ្នា។ រីឯលោកស្រីអ៊ិល ផាន ដែលធ្វើជាតំណាងអាណាព្យាបាល បានលើកឡើងដូចជាលោកមេភូមិខាងលើដែរ និងបានថ្លែងអំណរគុណ ចំពោះលោកបូជាចារ្យបងស្រី លោកគ្រូ អ្នកគ្រូ ដែលស្ម័គ្រចិត្តទាំងអស់ ដែលបានបើកវគ្គនេះឡើង។ ក៏សូមបញ្ជាក់ថា លោកគ្រូ អ្នកគ្រូ ទាំងអស់ស្ម័គ្រចិត្តទៅបង្រៀនប្អូនរាល់ថ្ងៃ ត្រូវទៅស្នាក់នៅ ក្នុងភូមិប៉ាងនេះតែម្តងនៅក្នុងរយៈពេលវិស្សមកាលរបស់ខ្លួន។ អ្នកទាំងនោះនឹងទទួលបាននូវការឧបត្ថម្ភជាថវិកាមួយចំនួនដើម្បីបន្តការសិក្សារបស់ខ្លួននៅក្នុងឆ្នាំបន្ទាប់ផងដែរ។ ពិធីត្រូវបានបញ្ចប់ដោយមានរាំរបាំផ្សេងៗ ដែលសម្តែងដោយសិស្សានុសិស្សនៅក្នុងវគ្គ និងមានចែកអំណោយជាសម្ភារៈសិក្សាដល់សិស្សដែលរៀនពូកែទាំងនោះដែរ។

លី សុវណ្ណា

### កម្មវិធីវគ្គបំប៉ន

ក្នុងវគ្គអប់រំបំប៉ននេះមានគ្រូស្ម័គ្រចិត្តដែលចេញមកពីមណ្ឌលសិស្សវិទ្យាល័យនៃព្រះសហគមន៍កំពង់ធំ។ កម្មវិធីនៅក្នុងវគ្គនេះមានការរៀបចំដូចតទៅ : ព្រឹកមានកម្មវិធីបង្រៀនអាន និងសរសេរអក្សរខ្មែរ។ ល្ងាចមានការបង្រៀនរបាំប្រពៃណីខ្មែរ ហើយនិងយប់មានកម្មវិធីអប់រំជំនឿសម្រាប់កូនចៅរបស់គ្រិស្តបរិស័ទ។ ព្រះសហគមន៍ភូមិប៉ាងគឺជាព្រះសហគមន៍តូចមួយដែលទើបបានកសាងឡើងក្នុងទសវត្សរ៍ទី៩០ ដោយគ្រិស្តបរិស័ទមួយចំនួន ដែលមានដើមកំណើតដំបូងនៅព្រះសហគមន៍កំពង់គោពីដើម និងបានទៅរស់នៅទីនោះដោយសារតែសង្គ្រាមស៊ីវិលផ្ទុះឡើង។

# យើងដើរតាមគន្លងនៃព្រះជាម្ចាស់

**មនុស្សម្នាក់ៗតែងមានគំនិត គោលបំណង និង ជំនឿខុសៗគ្នា។ នៅពេលដែលអ្នកនោះទុកចិត្ត ឬជឿស៊ប់ទៅលើអ្វីដែលគេគោរពហើយនោះ ទោះបីជាពួកគេជួបនូវផលលំបាកយ៉ាងណាក្តី ក៏ពួកគេពុះពារគ្រប់ឧបសគ្គដើម្បីរក្សាជំនឿនោះដែរ។**



លោកបូជាចារ្យ ពេដ្រូ ហ្គោមេ ឆ្លើយសំនួរទាក់ទងនឹងព្រះសហគមន៍

Photo: H. Sokhteary

សំណួរ ៖ តើមានចំនុចអ្វីខ្លះដែលធ្វើឱ្យអ្នកជឿ កាន់តែជឿខ្លាំងឡើងនៅក្នុងព្រះសហគមន៍កាតូលិក ?

លោកបូជាចារ្យ ពេដ្រូ៖ ខ្ញុំសូមអរគុណដល់ម្ចាស់សំណួរ។ មានចំនុចជាច្រើនដែលធ្វើឱ្យអ្នកជឿ រឹតតែជឿខ្លាំងនៅក្នុងគ្រិស្តសាសនា។ នេះគឺអាស្រ័យទៅលើគ្រិស្តបរិស័ទម្នាក់ៗ។ ចំនុចទី១ ការទំនាក់ទំនងជាមួយព្រះជាម្ចាស់ តាមរយៈការអធិដ្ឋាន ដែលធ្វើឱ្យអ្នកជឿមានអារម្មណ៍ថា ព្រះជាម្ចាស់ស្រលាញ់ និងស្ថិតនៅក្នុងខ្លួនរបស់ពួកគេ។ ការទំនាក់ទំនងជាមួយព្រះអង្គយ៉ាងជិតស្និទ្ធផ្តល់កម្លាំងដល់អ្នកជឿ ឱ្យពួកគេរឹតតែមានជំនឿខ្លាំងឡើង។ ចំនុចទី២ គឺបទពិសោធន៍នៃគ្រិស្តបរិស័ទ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជួយបងប្អូនក្នុងការរស់នៅ ការអប់រំដល់កូនក្នុងក្រុមគ្រួសារ និងការកសាងក្រុមគ្រួសារឱ្យមានសុភមង្គល។ បទពិសោធន៍របស់គ្រិស្តបរិស័ទ និងព្រះបន្ទូលព្រះជាម្ចាស់ នាំបងប្អូនឱ្យស្គាល់ព្រះជាម្ចាស់កាន់តែជ្រាលជ្រៅ។ ម្យ៉ាងទៀតព្រះបន្ទូលជួយបំភ្លឺចិត្តគំនិតអ្នកជឿ លើព្រះអង្គ។ ចំនុចទី៣ គឺការអប់រំល្អធ្វើឱ្យអ្នកជឿលើព្រះអង្គដើរតាមផ្លូវល្អ និងមានការរស់នៅសមរម្យ។ ចំនុចទី៤ ការជួបជុំគ្នាអធិដ្ឋាន និងថ្វាយអភិបូជារាល់ថ្ងៃអាទិត្យ ឬការធ្វើពិធីបុណ្យផ្សេងៗ អាចផ្តល់កម្លាំងចិត្តដល់អ្នកជឿ រហូតដល់មានអារម្មណ៍ថា យើងគឺជាគ្រិស្តបរិស័ទនិងជាមហាគ្រួសារតែមួយក្នុងនាមព្រះគ្រិស្ត។ ចំនុចទី៥ ការសម្តែងធម៌មេត្តាករុណាដល់អ្នកដទៃ ជួយជនក្រីក្រ សួរសុខទុក្ខអ្នកជំងឺ និងសាមគ្គីគ្នា ដែលទាំងនេះជួយពង្រឹងជំនឿដល់អស់អ្នកជឿលើព្រះអង្គ ហើយក៏ឱ្យពួកគេប្រព្រឹត្តតាមជំនឿ។ ចំនុចទាំងនេះជួយឱ្យអស់បងប្អូនដែលជឿ លើព្រះអង្គ ហើយមានជំនឿកាន់តែខ្លាំងឡើងៗ ជាប្រចាំថ្ងៃ។

សំណួរ ៖ តើយើងត្រូវជួយដល់បងប្អូនគ្រិស្តបរិស័ទទាំងនោះដូចម្តេចខ្លះ ?

លោកបូជាចារ្យ ពេដ្រូ៖ ទី១ គឺជួយណែនាំក្នុងការរស់នៅ មានន័យថា ឱ្យមានការទទួលការអប់រំល្អ ដើម្បីឱ្យមានការរស់នៅល្អក្នុងសង្គម ក្នុងភូមិដែលបងប្អូនរស់នៅ។ ទី២ គឺឱ្យបងប្អូនចេះគិតពីអ្នកដទៃ ពិសេសគឺអ្នកខ្វះខាត អ្នកជំងឺ អ្នករស់នៅជុំវិញបងប្អូន មានន័យថា ឱ្យសម្តែងទាំងក្តីស្រលាញ់ និងក្តីមេត្តា។ នេះគឺជាចំនុចសំខាន់ៗ នៅក្នុងព្រះសហគមន៍របស់យើង ដែលឱ្យគ្រិស្តបរិស័ទរបស់យើង មានជំនឿកាន់តែខ្លាំងឡើងៗ។ តាមបន្ទូលរបស់ព្រះអង្គ ព្រះយេស៊ូបានធ្វើ ហើយយើងជាគ្រិស្តបរិស័ទ យើងត្រូវធ្វើតាមព្រះយេស៊ូដូចដែលព្រះអង្គបានធ្វើរហូតដល់បូជាជីវិតរបស់ព្រះអង្គ។

មុំ គន្ធា

## ស្រាយចម្ងល់

ប្រសិនបើប្រិយមិត្តអ្នកអាន អ្នកនាំសារ មានចម្ងល់ ឬមានសំណួរទាក់ទងទៅនឹងព្រះសហគមន៍កាតូលិក ក៏ដូចជារឿងរ៉ាវ ដែលប្រិយមិត្តមិនទាន់យល់ច្បាស់អំពីព្រះជាម្ចាស់។ ប្រិយមិត្តអាចសរសេរជាសំណួរមកការិយាល័យ អ្នកនាំសារ តាមរយៈលោកបូជាចារ្យនៅជិតបំផុត ឬទូរស័ព្ទលេខ៖ ០១៦ ៣២៦ ៧៣៧ /០១២ ៣៣៨ ៩៨៥។ យើងខ្ញុំនឹងបកស្រាយជូនប្រិយមិត្តតាមរយៈការអញ្ជើញលោកបូជាចារ្យនានានៃភូមិភាគទាំងបី។

**កែតម្រូវសំណួរខែកញ្ញា៖ ប្រទេសអ៊ីស្រាអែលមានចម្ងាយប៉ុន្មានគ.មពីកម្ពុជា? តើភូមិកំណើតរបស់ព្រះយេស៊ូឈ្មោះអ្វី?**

ចេញពីកម្ពុជាតាមផ្លូវគោក គឺត្រូវឆ្លងកាត់ប្រទេស ថៃ ភូមា ឥណ្ឌា ប៉ាគីស្ថាន អាហ្គានីស្ថាន អ៊ីរ៉ាក់ ស៊ីរី ទើបដល់អ៊ីស្រាអែល (គឺប្រហែលជា ១ម៉ឺនគ.ម)។ ភូមិកំណើតព្រះយេស៊ូ គឺ បេថ្លេហិម ហើយព្រះយេស៊ូធំធាត់ឡើងគឺនៅស្រុកណាសារ៉ែត។





# ដើមស្រកានាគទុំក្រហម

**កាលពីមុនៗ ប្រជាជនខ្មែរ ធ្លាប់តែឃើញផ្លែស្រកានាគទុំមានសាច់ស ដែលនាំចូលពីប្រទេសជិតខាងមានថៃ និងវៀតណាមជាដើម។ ប៉ុន្តែសព្វថ្ងៃ នៅភូមិត្រពាំងលើក ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ មានចំការផ្លែស្រកានាគមួយ ដែលមានផ្លែទុំ មានសាច់ពណ៌ក្រហមគួរឱ្យចង់ទទួលទាន។**



អ្នកនាងស្រី លីនណា

តាមសំដីអ្នកនាងស្រី លីនណា ម្ចាស់ចំការផ្លែស្រកានាគនេះ បានឱ្យដឹងថា ដើមស្រកានាគដែលគាត់យកមកដាំនេះ គឺនាំចូលមកពីកោះចិនតៃវ៉ាន់តាំងពីចុងឆ្នាំ២០០២។ វាជាស្រកានាគទុំសាច់ក្រហម ដែលមានទំហំតូចជាង តែមានរសជាតិផ្អែមជាងស្រកានាគទុំសាច់ស។ អ្នកនាងបានប្រាប់ឱ្យដឹងអំពីបច្ចេកទេសដាំរុក្ខជាតិនេះ មានដូចតទៅ៖

ទី១ ការជ្រើសរើសប្រភេទដី ត្រូវស្វែងរកដីទីទួល ដែលមិនលិចទឹកតាមរដូវ និងជាប្រភេទដីល្បាយ។

ទី២ ការប្រើប្រាស់ជី គួរតែប្រើជីធម្មជាតិ ដែលមានដូចជាជីកំប៉ុស ឬអាចម៍គោ។ បើជាជីអាចម៍មាន់ ឬអាចម៍ប្រជៀវ ប្រើតែបន្តិចបន្តួចបានហើយ។

ទី៣ ទីតាំងដាំ ស្វែងរកកន្លែង ដែលអាចទទួលកម្តៅថ្ងៃបានគ្រប់គ្រាន់ល្មម។

ទី៤ របៀបដាំ ជីករណ្តៅរង្វង់មូល មានអង្កត់ផ្ចិតកន្លះម៉ែត្រ និងជម្រៅកន្លះម៉ែត្រ ហើយយើងក៏ជីក ចន្លោះពីរណ្តៅមួយទៅរណ្តៅមួយត្រូវរក្សាគម្លាត២ម៉ែត្រកន្លះ។ នៅក្នុងរណ្តៅយកដីលាយ ជីកំប៉ុស ២៥% និងជីអាចម៍គោ ២៥% ហើយនិងអង្កាមពី១០% ទៅ១៥% ទៀតដែរ។ យើងអាចដាក់ជីអាចម៍មាន់ និងអាចម៍ប្រជៀវបន្តិចបន្តួចថែមទៀត។ យើងត្រូវរកបង្គោលគ្រាក់ៗ ដែលអាចធន់បានរយៈពេល ១០ឆ្នាំ ប្រវែង ២ម៉ែត្រកន្លះ ដាក់ចូលក្នុងរណ្តៅកាយដីលាយជីចូលក្នុងរណ្តៅវិញ ជាន់ឱ្យណែនពុំបាច់ពេញរណ្តៅពេកទេ ដែលអាចរក្សាទឹកបានពេលស្រោចស្រព។ បន្ទាប់មកត្រូវកប់កូនស្រកានាគក្បែរបង្គោល ក្នុងមួយគុម្ព៤ដើម ដោយចងផ្អោបទៅនឹងបង្គោលដើម្បីដល់ពេលលូតលាស់ ឫសវាអាចតោងបង្គោលបានងាយស្រួល។

ទី៥ ការធ្វើទ្រើង យកដងឈើគុណភាពល្អ កាត់ប្រវែង មួយម៉ែត្រ ២តឹក ពីរកំណាត់ វាយខ្វែងជាប់ចុងបង្គោល។ បន្ទាប់មកយកកូនឈើ៤កំណាត់ ទៀតវាយភ្ជាប់ពីចុងម្ខាងទៅចុងម្ខាងទៀត (សូមមើលរូប)។

ទី៦ ការថែទាំ ពេលលូតលាស់ខ្ពស់ គឺត្រូវចងផ្អោបដើមទៅនឹងបង្គោលជាបន្តបន្ទាប់។ បើពន្លកខ្នែង ចេញពីដើមស្រកានាគផ្នែកខាងក្រោមទ្រើង ត្រូវកាត់ចេញ និងស៊កចុងវាចូលក្នុងប្រឡោះឈើខ្វែង។ ខ្នែងដែលចេញនូវពន្លកចាប់ពីផ្នែកខាងលើទ្រើងត្រូវរក្សាទុក។ ស្រោចទឹកឱ្យទៀងទាត់ ធានាសំណើមគល់ និងសំអាតស្មៅជុំវិញគល់ផង។ បើមានលទ្ធភាព ក្នុងរយៈពេល ៣ខែ បន្ថែមជីម្តង។ រយៈពេល ១០ឆ្នាំ ត្រូវគាស់ចេញ ហើយដាំសាជាថ្មី។

អ្នកនាងស្រី លីនណាបានបញ្ជាក់ឱ្យដឹងថា របៀបដាំខាងលើនេះ គឺចេះមកអំពីជនជាតិចិនតៃវ៉ាន់ និងបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការដាំដុះកន្លងមក។ អ្នកនាងបន្តថា ធ្វើចំការស្រកានាគរាល់ថ្ងៃនេះ មិនមែនអាជីវកម្មធំដុំនៅទេ គឺគ្រាន់តែផ្សាំកូនមែកលក់។ ចំណែកផ្លែទុកគ្រាន់តែទទួលភ្ញៀវ។

ផាត សំភី

## សារៈសំខាន់នៃផ្លែស្រកានាគ

វាជំនួយឆ្អឹម សួត និងប្រព័ន្ធរំលាយអាហារ យើងឱ្យបានរឹងមាំ និងការពារការទល់លាមកដែរ។ ម្យ៉ាងទៀតអ្នកជំងឺទឹកនោមផ្អែមក៏អាចបរិភោគបាន។ ដូច្នេះ បើបងប្អូនចាប់អារម្មណ៍ចង់ដាំរុក្ខជាតិនេះ សូមទាក់ទងអ្នកនាងស្រី លីនណា តាមទូរស័ព្ទ៖ ០១២ ៣២១ ៣៤៥។



បើមានលទ្ធភាពយើងអាចដាក់ល្អធ្វើជារណ្តៅក៏បានដើម្បីរក្សាទឹកឱ្យល្អ

Photos: P. Samphy

## រូបទាំងពីរខាងក្រោមនេះមាន ១២ចំនុចខុសគ្នា។ សូមប្រិយមិត្តស្វែងរក តើចំនុចទាំងនោះនៅទីកន្លែងណាខ្លះ ?





# ជំងឺបាក់ឆ្អឹង

ឆ្អឹងក៏ជាផ្នែកមួយដ៏សំខាន់សម្រាប់ទ្រទ្រង់រាងកាយមនុស្ស ហើយដើម្បីឱ្យឆ្អឹងរបស់យើងមានសុខភាពល្អ យើងត្រូវចេះប្រុងប្រយ័ត្នកុំឱ្យមានគ្រោះថ្នាក់ ដែលបណ្ដាលឱ្យវាបាក់បែកជាដើម។

លោកវេជ្ជបណ្ឌិតជួង ប៊ុណ្ណ នៃមន្ទីរពេទ្យព្រះកុសុមៈពន្យល់ពីបញ្ហាបាក់ឆ្អឹងថា: "ជំងឺបាក់ឆ្អឹងមានពីរប្រភេទ គឺបាក់ចំហ និងបាក់បិទជិត"។ លោកបន្តទៀតថា ការបាក់ចំហមានសភាពធ្ងន់ធ្ងរជាងបាក់បិទជិត ព្រោះកន្លែងចំហអាចឱ្យមេរោគចូល។ ពេលបាក់ចំហ ស្បែកវាដាច់ សាច់ដាច់ ឃើញដល់ឆ្អឹង ពេលនោះមេរោគអាចចូលដល់ក្នុង វាបណ្ដាលឱ្យកើតជាជំងឺរលាកឆ្អឹង រលាកខួរឆ្អឹង តេតាណូស ជំងឺគិស (ពិស) ឬវាធ្វើឱ្យរលេះរលួយស្បែករហូតគ្រោះថ្នាក់ដល់ជីវិត។

ចំពោះជំងឺបាក់បិទជិត មិនមានភាពធ្ងន់ធ្ងរទេ ប៉ុន្តែបើយើងពុំបានព្យាបាលឱ្យបានត្រឹមត្រូវ វាអាចប៉ះពាល់ដល់ការងាររកស៊ីរបស់យើងដែរ ឧបមាពេលបាក់ជើង បើយើងព្យាបាលមិនបានត្រឹមត្រូវ ពេលជា ជើងទៅអាចខ្លី លំបាកធ្វើដំណើរជាដើម។ ជំងឺបាក់បិទជិតជាជំងឺបាក់ធម្មតា ព្រោះឆ្អឹងវាអាចផុះដោយខ្លួនវា និងជាប់ដោយខ្លួនវា។ មានន័យថា គ្រប់ការបាក់បែក ឱ្យតែស្បែកបិទជិត ឆ្អឹងនឹងផុះឡើងដោយឯកឯង ដោយគ្រាន់តែខ្លះបានត្រង់ និងខ្លះកោង។

បើឆ្អឹងបាក់ជ្រួស ឬវៀចល្មម គ្រូពេទ្យអាចទាញតម្រង់ឆ្អឹងឱ្យត្រឹមត្រង់ដោយអបនឹងស៊ីម៉ង់ស៍ ឱ្យត្រង់ ដូចសភាពដើមវិញបាន។ ប៉ុន្តែបើបាក់ផ្លាស់ប្ដូរទីកន្លែងខ្លាំង វាទៅជាខ្លី ឬក៏វៀចខ្លាំង ពេលនោះគ្រូពេទ្យត្រូវអបនឹងដែកដោយការដាក់ដែកបញ្ចូលទៅក្នុងឆ្អឹង ឬដាក់អបពីក្រោយឆ្អឹង។

កាលណាឃើញនរណាម្នាក់មានគ្រោះថ្នាក់បាក់ឆ្អឹង យើងគួររកអ្វីមួយអបកន្លែងបាក់នោះ ដើម្បីកុំឱ្យឆ្អឹងធ្វើចលនា។ បើឆ្អឹងនោះធ្វើចលនា វាអាចធ្វើឱ្យកន្លែងរបួសនោះ ចំហស្បែក ឬក៏ឆ្អឹងចាក់ចំសរសៃដែលអាចធ្វើឱ្យដាច់សរសៃ។ យើងគួរតែអបកន្លែងបាក់នោះ ហើយបើកន្លែងនោះចំហ យើងគួរតែយកក្រណាត់គ្រប ហើយបញ្ជូនគាត់មកកាន់មន្ទីរពេទ្យ។

មុំ គន្ធា និងសំភី




Photo: P. Samphy

លោកវេជ្ជបណ្ឌិតជួង ប៊ុណ្ណ នៅមន្ទីរពេទ្យព្រះកុសុមៈ

### សង្គ្រោះបន្ទាន់

បើមានជនរងគ្រោះថ្នាក់បាក់ឆ្អឹង គេអាចជូនជនរងគ្រោះទៅមន្ទីរពេទ្យព្រះកុសុមៈ នៅអគារលេខ២៨ ផ្លូវយោធពលខេមរភូមិន្ទ ភ្នំពេញ ឬទូរស័ព្ទឡានពេទ្យ: ០១២ ៦៥៧ ៦៥៣។



# ចម្លាក់បដិមា

បើយើងធ្វើដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ 6A ទៅកាន់ទីរួមខេត្តកំពង់ធំ ដល់ភូមិសំណាក ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ យើងឃើញមានគេហដ្ឋាន ៥-៦ សុទ្ធតែប្រកបរបរចម្លាក់។



Photo: P. Samphy

ជាងចម្លាក់ប្រើញញួរ និងដែកដាប់ដើម្បីឆ្លាក់នូវរូបបដិមាព្រះពុទ្ធ

ស្នូរសំឡេងញញួរនឹងដែកដាប់ ដាប់លើថ្មឮស្នូរឆឹកៗ លាន់ឮល្វើយៗនៅពេលដែលយើងទៅដល់ទីនោះ។ យើងក៏នឹងនឹកស្រមៃថា ការងារចម្លាក់នេះប្រហែលជាលំបាកហើយព្រោះត្រូវប្រើកម្លាំងធ្វើការ នៅក្រោមកម្ដៅថ្ងៃ ដែលមានញើសហូរសស្រាក់។ ជាការពិតណាស់ លោកទិច ធៀម ដែលជាមេជាងចម្លាក់នៅគេហដ្ឋានមួយ រៀបរាប់ថា: "មែន! មុខរបរចម្លាក់នេះ នឿយណាស់ តែទោះជាយ៉ាងណា ក៏វាអាចធ្វើឱ្យយើងដោះស្រាយជីវភាពបានដែរ ជាជាងយើងទៅរកស៊ីបោកប្រាស់អ្នកដទៃ"។

ជាមួយកន្លែងដែលប្រៀបបាននឹងភូមិថ្ម យើងឃើញមានរូបសំណាកផ្សេងៗ ធ្វើពីថ្ម ដូចជារូបព្រះពុទ្ធអង្គ តាឥសី រូបតោ នាគ និងបដិមាផ្សេងៗ ជាច្រើនទៀត ដែលភាគច្រើន ទាក់ទងនឹងវិស័យសាសនាព្រះពុទ្ធ។ ថ្មសម្រាប់ចម្លាក់ទាំងនោះមានបីប្រភេទ គឺថ្មស ថ្មខៀវ និងថ្មក្រហម។ ថ្មទាំងនេះ គេយកមកពីភ្នំសន្ទុកដែលនៅតំបន់នោះស្រាប់ ហើយខ្លះទៀតយកមកពីខេត្តបន្ទាយមានជ័យដែរ។

លោកតិច ធៀម បន្តទៀតថា រូបប្រភេទណា ក៏ជាងចម្លាក់យើងនៅទីនេះអាចឆ្លាក់បានដែរ ឱ្យតែអតិថិជនត្រូវការ ពីព្រោះយើងបានរៀនជំនាញនេះរួចហើយ នៅសាលារចនា ទីក្រុងភ្នំពេញ។ មុនពេលឆ្លាក់ អតិថិជនគេយករូបថតមកឱ្យយើង។ យើងនឹងឆ្លាក់ ឱ្យដូចជារូបនោះ ទាំងទំហំ និងក្បាច់ចម្លាក់។ ប៉ុន្តែក៏មានរូបដែលលំបាកឆ្លាក់ដែរ ដូចជា រូបព្រះសិអារមេត្រី ដែលមានក្បាច់ក្បូរច្រើននៅលើសម្លៀកបំពាក់ និងគ្រឿងអលង្ការជាដើម។

ដើម្បីធ្វើឱ្យមុខរបរចម្លាក់បានរីកចម្រើន ជាងចម្លាក់ត្រូវគិតសម្រិតសម្រាំងនូវទឹកដៃរបស់ខ្លួនឱ្យបានស្អាត ធ្វើការដោយផ្ចិតផ្ចង់ និងប្រិតប្រៀង។ម្យ៉ាងទៀតយើងត្រូវខំបំពេញចិត្តអតិថិជន។ ជួនកាលពេលឆ្លាក់ហើយ អតិថិជនមិនពេញចិត្ត ហើយប្រាប់ឱ្យកែកុនឡើងវិញ ជាងចម្លាក់ត្រូវធ្វើឡើងវិញតាមនោះ កុំបីតវ៉ាប្រកែកឡើយ។

តម្លៃរូបចម្លាក់ថ្លៃ ឬថោក អាស្រ័យលើទំហំ និងប្រភេទថ្ម។ រូបធំ និងធ្វើពីថ្មខៀវមានតម្លៃថ្លៃ។ រូបខ្លះមានដល់រាប់ម៉ឺនដុល្លារ។ រីឯរូបតូចបំផុតក៏មានតម្លៃ ១៥ដុល្លារ ដែរ។

ផាត សំភី

### រៀនចម្លាក់

នៅសាលាជាតិរចនានៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឡូត៍លេខ ៧២ ផ្លូវលេខ ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ រៀនបង់ថ្លៃមួយឆ្នាំ ៣០០ដុល្លារ សិស្សត្រូវមានអាយុ ១៥ ឆ្នាំឡើង មិនគិតកម្រិតវប្បធម៌។ រៀនអាហារូបករណ៍ សិស្សប្រឡងចូល ក្រោយពីបញ្ចប់សាលាចំណេះទូទៅថ្នាក់ទី៩។ ទូរស័ព្ទព័ត៌មាន: ០១២ ៨៣៥ ២៧៤។

# លោកជា ងុយ: "ខ្ញុំមិនអាចសុំទានគេដើម្បីចិញ្ចឹមជីវិតឡើយ"


Photo: M. Kunthear

លោកជា ងុយ អង្គុយសម្លឹងជញ្ជីងជីវិតខ្លួន

**ជីវិតគឺជាការតស៊ូ ហ៊ានពុះពារគ្រប់បែបយ៉ាងដើម្បីជីវិតដោយមិនខ្លាចពិបាក និងខ្មាស់អៀន។ ទោះបីរូបកាយពិការ តែលោកជា ងុយមិនឱ្យពិការចិត្តឡើយ។**

លោក ជា ងុយ ត្រូវក្រោកពីដំណេក តាំងពីម៉ោង៤ព្រឹក ដើម្បីរៀបចំខ្លួន ធ្វើដំណើរមកកាន់កន្លែងធ្វើការរបស់គាត់ ដែលនៅឆ្ងាយពីផ្ទះ។ លោកជា ងុយ ពុំមែនជាអ្នកធ្វើការងារធំ ឬជាអ្នកជំនួញអ្វីនោះទេ គាត់ជាអ្នកដាក់ជញ្ជីង សម្រាប់ថ្លឹងទម្ងន់មនុស្សម្នាតែប៉ុណ្ណោះ។ លោកងុយ គឺជាជនពិការមួយរូបដែលព្យាយាមតស៊ូក្នុងជីវិត ហើយក៏មិនមែនដើម្បីតែជីវិតគាត់ម្នាក់នោះដែរ គឺក៏សម្រាប់ជីវិតប្រពន្ធ និងកូន៣នាក់របស់គាត់ផងដែរ។

លោកជា ងុយ ធ្លាក់ខ្លួនពិការតាំងពីជំនាន់ប៉ុលពតមកម្ល៉េះ ដោយសារពួកខ្មែរក្រហមចាក់ថ្នាំឱ្យស្វិតជើងទាំងសងខាង។ ទោះជាគាត់គ្មានសមត្ថភាពក្នុងការដើរបានដូចមនុស្សធម្មតាក៏ដោយ តែគាត់មានការព្យាយាម និងតស៊ូគ្រប់បែបយ៉ាង ដែលមនុស្សជាច្រើន កោតសរសើរចំពោះភាពអត់ធ្មត់របស់គាត់គ្រប់ៗគ្នា។ បុរសពិការភាពរូបនេះមានមោទនភាពចំពោះខ្លួនយ៉ាងខ្លាំងដោយលោកបានមានប្រសាសន៍ថា: "ខ្ញុំមិនសុំទានជាដាច់ខាត ខ្ញុំមានការអៀនខ្មាស់ខ្លាំងណាស់"។ ជាធម្មតា ក្នុងមួយថ្ងៃ លោកជា ងុយ មានលទ្ធភាពអាចធ្វើការរកចំនូលបានពី៧០០០រៀល ទៅ៨០០០រៀល។

ក្នុងសភាពទម្លាក់ទឹកមុខបន្តិចលោកជា ងុយ បន្តថា ពីមុន គាត់ធ្លាប់បានរកស៊ីលក់ចាប់ហួយបន្តិចបន្តួចនៅផ្ទះ តែអ្នកទិញជំពាក់លុយមិនព្រមសងធ្វើឱ្យក្រុមគ្រួសារគាត់ពិបាក។ ចាប់ពីពេលនោះមកគាត់មិនចង់រកស៊ីទៀតទេ។ គាត់ចាប់ផ្ដើមរកស៊ីដាក់ជញ្ជីងថ្លឹងមនុស្ស តាំងតែពីឆ្នាំ២០០២មកដោយមានម៉ូតូឌុប និងស៊ីក្លូជូនម៉ូយមក រៀងរាល់ថ្ងៃ។ គាត់ដាក់ជញ្ជីងនៅមុខវាំង រហូតដល់ម៉ោង១០យប់ ទើបវិលត្រលប់ទៅផ្ទះវិញ។

កំពុងអង្គុយចាំម៉ូយលើម៉ូតូ នៅក្បែរនោះ និងជាម៉ូយរបស់ជា ងុយផងដែរ គាត់និយាយថា លោកងុយ ជាមនុស្សមានចរិតសុភាពរាបសា និងពុំចេះរញ៉េរញ៉ៃជាមួយអ្នកដទៃឡើយ។ នៅពេលទំនេរបុរសពិការរូបនេះចូលចិត្តជួយកិច្ចការភរិយា និងកូនផងដែរ។ គាត់បាននិយាយ ដោយរាងអៀនៗថា: "ខ្ញុំចូលចិត្តជួយដាំបាយប្រពន្ធខ្ញុំ ព្រោះខ្ញុំមិនសូវបានជួយគេប៉ុន្មានឡើយ"។ ភរិយារបស់គាត់មិនមានមុខរបរអ្វីទេ ដោយសារតែបទពិសោធន៍រកស៊ីកន្លងមក។ គាត់សម្រេចឱ្យប្រពន្ធនៅផ្ទះ។

លោកជា ងុយ ក៏និយាយដោយអស់សំណើចថា: "ខ្ញុំឃើញអ្នកខ្លះមានកាយសម្បទាគ្រប់គ្រាន់ តែដើរសុំទានគេ មើលទៅ! ប្រហែលជាពួកគេមិនដឹងរករបរអ្វីហើយ។ ចំពោះខ្ញុំ មិនចេះហុចដៃសុំគេទេ ជាពិសេសភ្ញៀវទេសចរបរទេស ពីព្រោះខ្ញុំខ្លាច គេនិយាយដើមពីប្រទេសយើង នៅពេលគេត្រឡប់ទៅស្រុកវិញ"។ នាសព្វថ្ងៃនេះ គាត់ខិតខំសន្សំលុយដើម្បីរៀបចំអនាគតកូនៗគាត់ ដោយគាត់ចង់ឱ្យពួកគេក្លាយទៅជាជាងកាត់ដេរ។

ហ៊ូ សុខធារី

## ព្រឹត្តិការណ៍នឹងមាន!

- រៀងរាល់មួយអាទិត្យម្ដង: គ្រិស្តបរិស័ទនៅព្រែកទំលជួបជុំគ្នាដើម្បីអធិដ្ឋានលើកតម្កើងព្រះជាម្ចាស់។
- រៀងរាល់ថ្ងៃសុក្រដើមខែ: ជូនព្រះកាយដល់គ្រិស្តបរិស័ទវ័យចាស់ជរានៅតាមផ្ទះនៅក្នុងរាជធានីភ្នំពេញ។
- ថ្ងៃទី០១ តុលា ម៉ោង ៩ព្រឹក: ពិធីជួបជុំចាស់ជរា និងទទួលអគ្គសញ្ញាលាបប្រេងនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច។
- ថ្ងៃទី០១ តុលា ដដែល: បវេសនកាល នៃវគ្គរៀនអប់រំជំនឿមនុស្សពេញវ័យនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច។
- ថ្ងៃទី៤-១១ តុលា: គ្រិស្តបរិស័ទនៅប្រទេសអូស្ត្រាលីជួយជួសជុលផ្ទះដល់គ្រួសារក្រីក្រចំនួន២៤ ទទួលខុសត្រូវដោយព្រះសហគមន៍សៀមរាប។
- ថ្ងៃទី០៦-១០ តុលា: លោកអភិបាលនៃភូមិភាគទាំងបី និងតំណាងគ្រប់សិទ្ធិមកចូលរួមប្រជុំពិភាក្សាគ្នា នៅព្រះសហគមន៍ផ្សារតូច-ភ្នំពេញ។
- ថ្ងៃទី០៨-១១ តុលា: សិក្ខាសាលាការ៉ូល និងសេដ្ឋា ដែលមានការចូលរួមពីឪពុកម្ដាយចំនួន ៣០គូ នៅកំពង់ចាមក្រុង ព្រះសហគមន៍ស្វូង និងក្ដុលលើ។
- ថ្ងៃទី១១-២៤ តុលា: ប្រជុំបូជាចារ្យបងស្រី និងគណៈកម្មការព្រះសហគមន៍ភូមិភាគបាត់ដំបង រិះគិតពីការរីកចម្រើនដំណើរការ និងផលប៉ះពាល់នៃព្រះសហគមន៍ក្នុងព្រះសហគមន៍នីមួយៗ យ៉ាងដូចម្ដេច? ធ្វើនៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី២៥-២៦ តុលា: គឺជាការប្រជុំមួយឆ្នាំម្ដងដើម្បីចែករំលែកបទពិសោធន៍រវាងលោកបូជាចារ្យ បងស្រី និងអ្នកស្ម័គ្រចិត្ត នៅព្រះសហគមន៍សៀមរាប។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ ហៃរណាន់ ពីនីយ៉ា